# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1228

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ផ្នែក ក

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : សិក្សាពីស្ថានភាពប្រភេទឈើគ្រញូង និងនាងនួននៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងលក្ខខណ្ឌអំណោយផលនានាក្នុងការគាំទ្រដល់ការបង្កើតនិងការចុះបញ្ជីចម្ការឈើ (គ្រញូង និងនាងនួន) លក្ខណៈឯកជនខ្នាតតូច

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/11/19 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/04/21 |
| ៣. ចំណាយគម្រោងសរុប | $149,800 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | Forestry Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលព្រៃឈើ |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានបញ្ចប់ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ការបន្តការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ
- ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងការការពារតំបន់ធម្មជាតិ ដោយផ្តោតលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ ដើម្បីធានាគុណភាពដី និងចីរភាពប្រភពទឹក
- ការបន្តអភិរក្ស និងអភិវឌ្ឍបេតិកភ័ណ្ឌវប្បធម៌ ដោយជំរុញការចុះបញ្ជី ពង្រឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ និងចងក្រង ព្រមទាំងបង្កើតតម្លៃពីបេតិកភ័ណ្ឌវប្បធម៌

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ព្រះវិហារ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ដើម្បីធ្វើការសិក្សាពីស្ថានភាពប្រភេទឈើក្រញូង និងនាងនួន នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងលក្ខខណ្ឌអំណោយផលនានាក្នុងការគាំទ្រដល់ការបង្កើត និងការចុះបញ្ជីចម្ការឈើដាំ (ក្រញូង និងនាងនួន) ជាលក្ខណៈឯកជនខ្នាតតូច។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

សិក្សាពីស្ថានភាពប្រភេទឈើក្រញូង និងនាងនួន នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងលក្ខខណ្ឌអំណោយផលនានាក្នុងការគាំទ្រដល់ការបង្កើតនិងការចុះបញ្ជីចម្ការឈើ (ក្រញូង និងនាងនួន) លក្ខណៈឯកជនខ្នាតតូច "Integrating the Development of Guidelines and Incentives for Piloting the Establishment of Small-scale Private Dalbergia Plantations with the Determination of a Non-detriment Findings Report in Choam Ksant district, Preah Vihear Province in Cambodia" បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋបាលព្រៃឈើ និងលេខាធិការដ្ឋាន CITES កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ហើយគម្រោងនេះបានទទួលថវិកាគាំទ្រដោយសហគមន៍អឺរ៉ុប និងអនុវត្តដោយរដ្ឋបាលព្រៃឈើ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

- គម្រោងបានធ្វើការសិក្សាវាយតម្លៃស្ថានភាពប្រភេទឈើកំពុងរងគ្រោះ ដែលរួមមានឈើក្រញូង និងនាងនួនក្នុងធម្មជាតិ ដើម្បីផ្តល់អនុសាសន៍សម្រាប់ ការអភិរក្ស
- គម្រោងបានចែកកូនឈើក្រញូងប្រមាណជាង ៥២.៥៥១ដើម ដល់សហគមន៍ និងឯកជនប្រមាណជាង៧៦៤គ្រួសារ ដើម្បីដាំជាចម្ការ កសិ-រុក្ខកម្ម (ដាំតាមរបង) និងដាំតាមទីសាធារណៈ ដែលមានសាលារៀន សាលាស្រុក ឃុំ និងស្នាក់ប៉ុស្តិ៍ប៉ូលីស និងទាហាន ជាដើម
- អ្នកពាក់ព័ន្ធ ត្រូវបានបណ្តុះបណ្តាលលើជំនាញពាក់ព័ន្ធសារពើភ័ណ្ឌប្រភេទឈើក្រញូង និងនាងនួន ក្នុងព្រៃធម្មជាតិ ក្នុងស្រុកជាំក្សាន្ត (តាមព្រំដែនថៃ និងឡាវ)។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

សិក្សាពីស្ថានភាពប្រភេទឈើក្រញូង និងនាងនួន នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងលក្ខខណ្ឌអំណោយផលនានាក្នុងការគាំទ្រដល់ការបង្កើតនិងការចុះបញ្ជីចម្ការឈើ (ក្រញូង និងនាងនួន) លក្ខណៈឯកជនខ្នាតតូច បានរួមចំណែកដល់ការអភិរក្សធនធានសេនទិចប្រភេទឈើដែលកំពុងរងការគំរាមកំហែងនៅក្នុងធម្មជាតិ ពិសេសពីការធ្វើអាជីវកម្មខុសច្បាប់ និងបានចែកចាយកូនឈើដល់សហគមន៍ និងគ្រួសារកងទ័ព ៧៦៤គ្រួសារ ដើម្បីសាកល្បងបង្កើតជាចម្ការឈើក្រញូងនៅក្នុងស្រុកជាំក្សាន្ត ដែលអាចជំរុញការចុះបញ្ជី ដើម្បីទទួលបានភាពស្របច្បាប់ និងការទទួលស្គាល់អំពីប្រភពនៃឈើដាំ សម្រាប់ការធ្វើអាជីវកម្មដោយស្របច្បាប់នៅក្នុងពេលអនាគត និងបានចូលរួមបំពេញកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងអនុសញ្ញាអន្តរជាតិសាយតេសស្តីពីការត្រួតពិនិត្យប្រភេទឈើរងគ្រោះដោយសាការធ្វើអាជីវកម្ម។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះបានជួយដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការចែកកូនឈើសម្រាប់ដាំជាចម្ការកសិ-រុក្ខកម្ម ដែលប្រជានឬសហគមន៍អាចប្រមូលផលទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ដែលជាផ្នែកមួយនៃការសន្សំពីប្រភពចំណូល និងការលើកស្ទួយបរិស្ថាននៅជុំវិញផ្ទះរបស់ខ្លួន ដែលសម្រេចបាននូវការអភិវឌ្ឍដោយចីរភាព ឬការអភិវឌ្ឍបៃតង។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **២. ព្រៃឈើ** | 70 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីក្នុងទីតាំងរបស់គម្រោងឡើយ ព្រោះសមាសភាពស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងតួនាទីជាមន្ត្រីគម្រោង និងសកម្មភាពនានារបស់គម្រោង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រីអនុវត្តគម្រោងមានជំនាញ សមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងសម្រេចបានសមិទ្ធិផលគួរឱ្យកត់សម្គាល់រួមមាន៖ ការចែកកូនឈើគ្រញូង និងឈើហូបផ្លែប្រមាណ ៥២.៥៥១ដើម ដល់សហគមន៍មូលដ្ឋានជាង ៧៦៤គ្រួសារ ឃុំចំនួន ៧ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ បានផ្សព្វផ្សាយ និងលើកទឹកចិត្តប្រជាជនឱ្យដាំប្រភេទឈើប្រណិត និងប្រភេទដែលបានចុះក្នុងឧបសម្ព័ន្ធសាយតេសតាមហ្វេសប៊ុករបស់រដ្ឋបាលព្រៃឈើចំនួន៥លើក ព្រមទាំងចុះត្រួតពិនិត្យស្ថានភាពកូនឈើដែលបានដាំរួច ដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃអាត្រារស់នៃការដាំកូនឈើគ្រញូងដែលបានចែកជូនដល់ប្រជាពលរដ្ឋ វត្តអារាម សាលារៀន។ ការរៀបចំគោលការណ៍ណែនាំស្តីពីការចុះបញ្ជីព្រៃឯកជន និងបានចងក្រងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងជីវសាស្ត្រ រប៉ាយ និន្នាការ ការប៉ាន់ស្មានមាឌឈើ ស្ថានភាព ការគ្រប់គ្រង និងការអភិរក្សឈើគ្រញូង និងនាងនួននៅក្នុងស្រុកជាំក្សាន្តខេត្តព្រះវិហារ។ គម្រោងក៏បានចូលរួមដាំកូនឈើគ្រញូងចំនួន ៤.៣៥០ដើម នៅតាមសាលារៀន និងវត្តអារាមនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដោយមានអ្នកចូលរួមសរុបប្រមាណ ៦៥០នាក់ ក្នុងនោះមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ទាហាន នគរបាលព្រំដែន ព្រះសង្ឃ មេធាវី និងប្រជាពលរដ្ឋ។

២៤. **អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

២៥. **ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះជាជំនួយពីសហគមន៍អឺរ៉ុប តាមរយៈ CITES Tree Species Programmer សម្រាប់រយៈពេល១៨ខែ ដោយគិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ ខែឧសភា ឆ្នាំ២០២១។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| European Commission | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 149.8 | 116.2 | 33.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: